វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១២ លេខ ០២

## កំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា៖ ការយកទ្រឹស្តីមកអនុវត្តជាក់ស្តែង[១]

"កំណើនដែលមានការចូលរួម ពិតជាមានសារៈសំខាន់ចំពោះរាជរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍នៅកម្ពុជា ជាពិសេសសម្រាប់យុវជន ប្រជាជនក្រីក្រ និងប្រជាជនដែលងាយរងគ្រោះ។"

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
*នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

### ទស្សនទាននៃកំណើនសម្រាប់គ្រប់គ្នា

កំណើនសេដ្ឋកិច្ចខ្ពស់ ជាមូលដ្ឋានគ្រឹះ និងជាវិធានការចម្បងបំផុតនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយជោគជ័យ។ ហេតុនេះ អ្នកបង្កើតគោលនយោបាយបានប្រឹងប្រែងជាយូរមកហើយ ដើម្បីបង្កើតលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលជួយជំរុញឲ្យមានកំណើនលឿន។

នាពេលបច្ចុប្បន្ន កាន់តែមានការទទួលស្គាល់ច្រើនឡើងថា ប្រសិនបើចង់ឲ្យមានកំណើនខ្ពស់ក្នុងរយៈពេលមធ្យម និងវែងនោះ ត្រូវមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីធានាថា កំណើននេះរីកដុះដាលដល់គ្រប់វិស័យ ប្រជាជន និងតំបន់ភូមិសាស្ត្រ។ កំណើនសម្រាប់គ្រប់គ្នានេះ វាតម្រូវឲ្យមានការផ្សារភ្ជាប់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រយ័ត្នប្រយែងទៅនឹងគោលនយោបាយសង្គម និងមីក្រូសេដ្ឋកិច្ច ដើម្បីធានាឲ្យកំណើននៅតែមានកម្រិតខ្ពស់ ប៉ុន្តែមាននិន្នាការប្រកបដោយសមធម៌។

កំណើនសម្រាប់គ្រប់គ្នា សំដៅដល់ការបង្កើតឱកាស និងការទទួលបានឱកាសគ្រប់គ្នា ជាពិសេស ប្រជាជនក្រីក្រ និងងាយរងគ្រោះ។ វាមិនតម្រូវឲ្យមានការបែងចែកទ្រព្យសម្បត្តិឡើងវិញរាល់លើកនោះទេ ប៉ុន្តែតម្រូវឲ្យមានការលើកកម្ពស់លទ្ធភាពស្មើគ្នាក្នុងទូទាំងប្រទេស ដើម្បីទទួលបានឱកាសល្អនេះ។

រដ្ឋាភិបាលមានតួនាទីកំណត់ក្របខ័ណ្ឌគោលនយោបាយនិងស្ថាប័ន ដើម្បីឲ្យប្រជាជនអាចចូលរួមបានច្រើន ក្នុងដំណើរលូតលាស់សេដ្ឋកិច្ច។ រូបភាព ១ បង្ហាញថា កំណើន ផសស ខ្ពស់ ដែលមានបំពេញបន្ថែមដោយប្រព័ន្ធសុវត្ថិភាពសង្គម ការអប់រំប្រកបដោយប្រសិទ្ធភាពនិងសមធម៌ និង ការថែទាំសុខភាពនិងអាហារូបត្ថម្ភកាន់តែប្រសើរ នឹងជួយបង្កើតឱកាសល្អផង ហើយប្រជាជនក៏មានស្ថានភាពល្អដើម្បីចាប់យកឱកាសទាំងនោះ និងជួយជំរុញសេដ្ឋកិច្ចទៅមុខ។

ការបង្កើនសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តប្រកបដោយតម្លាភាព ពង្រឹង និង ពិនិត្យតាមដានក្របខ័ណ្ឌគោលនយោបាយសម្រាប់ជួយដល់គ្រប់គ្នានេះ គឺជាកត្តាដ៏សំខាន់បំផុតសម្រាប់ធានាឲ្យមានកំណើនខ្ពស់ មានចីរភាព និងសម្រាប់គ្រប់គ្នានៅកម្ពុជា។

### តើកំណើនសេដ្ឋកិច្ចនៅកម្ពុជា ហូរចូលសម្រាប់គ្រប់គ្នាឬទេ?

តាមគ្រប់សញ្ញាដែលអាចមើលឃើញ កម្ពុជាបានជឿនលឿនគួរឲ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ ដោយមានកំណើនសេដ្ឋកិច្ចខ្ពស់ សម្រាប់គ្រប់គ្នា និងមានចីរភាព។

ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) បង្ហាញថា អនុបាតនៃភាពក្រីក្រនៅកម្រិតខ្សែបន្ទាត់ភាពក្រីក្រជាតិបានធ្លាក់ចុះដល់ ៣០,១% នៅឆ្នាំ២០០៧ ធៀបនឹង ៤៧% នៅឆ្នាំ១៩៩៤។ ការវិភាគនាពេលថ្មីៗផ្អែកលើទិន្នន័យបានពីអង្កេតជាបន្តបន្ទាប់របស់ CDRI បានរកឃើញថា ភាពក្រីក្រធ្លាក់ចុះ ១០ឯកតាភាគរយ ក្នុងចន្លោះឆ្នាំ២០០១ និង ២០១១។

និន្នាការរួម បានបង្ហាញច្បាស់ពីការធ្លាក់ចុះភាពក្រីក្រក៏ពិតមែន ប៉ុន្តែក្រៅពីនេះទិន្នន័យហាក់កាន់តែស្រពេចស្រពិលឡើង។ អ្នកស្រាវជ្រាវក៏ចាប់ផ្តើមចោទសួរពីភាពត្រឹមត្រូវ និងសុពលភាពនៃឧបករណ៍បច្ចុប្បន្នដែលសម្រាប់វាស់វែងកំណើនសម្រាប់គ្រប់គ្នាដែរ។ ដោយឡែក ការវិភាគជាបន្តបន្ទាប់នៅ CDRI បានចោទសួរថា តើទិន្នន័យ CSES គ្រប់គ្រាន់ឬទេ សម្រាប់ការគណនាពីបម្រែបម្រួលភាពក្រីក្រនិងវិសមភាពពីមួយឆ្នាំទៅមួយឆ្នាំ។

សំណុំទិន្នន័យ CSES ជាគំរូតាងប្រើប្រាស់ញឹកញាប់ជាងគេ ដើម្បីគណនា និងពិពណ៌នាពីទិដ្ឋភាពផ្សេងៗនៃការអភិវឌ្ឍនៅកម្ពុជា។ ប៉ុន្តែ

---

១ អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ បកស្រាយដោយ បណ្ឌិត តុង គឹមស៊ុន សេដ្ឋវិទូជាន់ខ្ពស់ និងអ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI ឯកឧត្តម ហង់ ជួន ណារ៉ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុប្រធានអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។

* ផលិតផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១២:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

រូបភាព ១៖ ក្របខ័ណ្ឌមួយនៃកំណើនសម្រាប់គ្រប់គ្នា




ប្រភព៖ Zhuang (2010) ដកស្រង់ពីក្នុងបទបង្ហាញរបស់បណ្ឌិត គុង គឹមស៊ុន ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា នៅថ្ងៃទី១៦ កុម្ភៈ ២០១២

កង្វះវិធីសាស្ត្រវាស់វែងឲ្យដូចៗគ្នាពីមួយឆ្នាំទៅមួយឆ្នាំ បានចោទបញ្ហាដល់ការប្រៀបធៀបតាមពេលវេលា ព្រោះវាអាចផ្តល់លទ្ធផលខុសឆ្គង ឬក៏ ផ្តល់ព័ត៌មានមិនពេញលេញដល់អ្នកបង្កើតគោលនយោបាយ។

CDRI បានប្រឹងប្រែងពុះពារបញ្ហាចោទខាងវិធីសាស្ត្រទាំងនេះ។ ទិន្នន័យបានពីអង្កេតបន្តបន្ទាប់សម្រាប់ឆ្នាំ ២០០១ ២០០៤/៥ ២០០៨ និង ២០១១ មិនជួបបញ្ហាភាពមិនទៀងទាត់ខាងវិធីសាស្ត្រនេះទេ ដូច្នេះវាមានប្រយោជន៍ជាងសម្រាប់ការវិភាគបែបប្រៀបធៀប។ គុណវិបត្តិមួយគឺគំរូតាងអង្កេតត្រឹមប្រមាណ ៧៩០គ្រួសារនេះ វាតូចជាងគំរូតាងរបស់ CSES។

សំណុំទិន្នន័យរបស់ CDRI និង CSES បង្ហាញលទ្ធផលផ្ទុយគ្នាខ្លាំងទាក់ទងនឹងទំហំនៃវិសមភាព និងអត្រាបម្រែបម្រួលវិសមភាពតាមពេលវេលា។ ទិន្នន័យ CSES បង្ហាញថា វិសមភាពបានកើនឡើងពីមេគុណ Gini ៣៨,២៨ ដល់ ៤៥,៣៧ នៅរវាងឆ្នាំ ១៩៩៤ និង ២០០៧[២]។ ផ្ទុយទៅវិញ ទិន្នន័យរបស់ CDRI បង្ហាញពីការធ្លាក់ចុះវិសមភាព និងអត្រាវិសមភាពជាទូទៅចុះទាបច្រើន គឺពីមេគុណ Gini ២៨,៦ ក្នុងឆ្នាំ២០០១ ដល់ ២៦,២ ក្នុងឆ្នាំ២០១១។ ដូច្នេះ ជាការសំខាន់ណាស់ដែលត្រូវធ្វើការស្រាវជ្រាវឲ្យបានកាន់តែហ្មត់ចត់ ដើម្បីកែតម្រូវភាពខុសគ្នារវាងសំណុំទិន្នន័យផ្សេងៗនេះចេញ។

ក្រៅពីបញ្ហាទិន្នន័យដូចខាងលើ មានកត្តាជាច្រើនទៀតបង្ហាញថា កំណើនសេដ្ឋកិច្ចនៅកម្ពុជា មិនទាន់បំពេញបានតាមគ្រប់លក្ខណៈវិនិច្ឆ័យនៃកំណើនសម្រាប់គ្រប់គ្នានោះទេ។

២ មេគុណ Gini ស្មើ ០ តំណាងឲ្យសមភាពពេញលេញ និង ១០០ តំណាងឲ្យវិសមភាពពេញលេញ។

ទី១ អត្រាកាត់បន្ថយភាពក្រីក្រ មិនបានដូចគ្នាទាំងអស់ នៅក្នុងប្រជាជនទាំងមូលទេ។ ទិន្នន័យរបស់ CDRI បង្ហាញថា យេនឌ័រនៃមេគ្រួសារ ជាកត្តាដ៏សំខាន់មួយដែលជះឥទ្ធិពលលើអត្រាកាត់បន្ថយភាពក្រីក្រ។ នៅចន្លោះឆ្នាំ ២០០១ និង ២០១១ ចំនួនគ្រួសារមានបុរសជាមេគ្រួដែលក្រីក្រ បានធ្លាក់ចុះ ១១,៨% រីឯចំនួនគ្រួសារមានស្ត្រីជាមេគ្រួដែលក្រីក្រ បានធ្លាក់ចុះត្រឹមតែ ៥,៥% ប៉ុណ្ណោះ។

ទិន្នន័យ CSES បង្ហាញពីភាពខុសគ្នារវាងប្រជាជនរស់នៅទីក្រុង និងជនបទ៖ នៅចន្លោះឆ្នាំ ២០០៤ និង ២០០៧ ចំនួនគ្រួសារក្រីក្ររស់នៅជនបទ បានធ្លាក់ចុះ ១១,១% ហើយចំនួនគ្រួសារក្រីក្ររស់នៅទីក្រុង បានធ្លាក់ចុះ ១៣,៣%។ ប្រសិនបើនិន្នាការបច្ចុប្បន្នមិនប្រែប្រួលទេ វិសមភាពរវាងតំបន់ជនបទនិងទីក្រុង និង រវាងគ្រួសារមានស្ត្រីជាមេគ្រួ និងមានបុរសជាមេគ្រួ នឹងកើនឡើងនៅពេលអនាគត។

ទី២ ទាក់ទិននឹងកំណើនសម្រាប់គ្រប់គ្នា ក្រៅពីការវាស់វែងតាមប្រាក់ចំណូលនេះ ប្រទេសកម្ពុជាសម្រេចបានលទ្ធផលមិនល្អទេ។ តារាង ១ បង្ហាញថា សន្ទស្សន៍កំណើនសម្រាប់គ្រប់គ្នារបស់កម្ពុជា មានកម្រិត "ល្អបង្គួរ" ក៏ពិតមែន ប៉ុន្តែវាផ្អែកលើការកាត់បន្ថយភាពក្រីក្រដែលជំរុញឡើងដោយអត្រា "ល្អប្រសើរ" នៃកំណើនសេដ្ឋកិច្ច និងអត្រាសឹងតែ "ល្អប្រសើរ" នៃចំណាយប្រើប្រាស់។ ប៉ុន្តែកត្តាផ្សេងទៀតដែលរួមចំណែកបង្កើតបរិយាកាសអំណោយផល ដូចជា កិច្ចការពារខាងសង្គមកិច្ចសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ ជាដើម នៅខ្វះខាតខ្លាំងណាស់។

សរុបមក ការវិភាគតាមពេលវេលាដោយប្រើ ទិន្នន័យមិនសូវមានបញ្ហាបានពីអង្កេតជាបន្តបន្ទាប់តាមពេលទៀងទាត់របស់ CDRI វាបង្ហាញពីការធ្លាក់ចុះវិសមភាព និងការកាត់បន្ថយភាពក្រីក្របានច្រើនគ្រប់គ្រាន់ដែលអាចចាត់ទុកថា និន្នាការទូទៅនៃការអភិវឌ្ឍន៍នៅកម្ពុជាគឺ

**តារាង១៖ សន្ទស្សន៍កំណើនសម្រាប់គ្រប់គ្នានៅប្រទេសកម្ពុជា**

| | ពិន្ទុ | ទម្ងន់ | សរុប |
|---|---|---|---|
| ១. កំណើន | 8 | 0.25 | 2.00 |
| ២. ភាពមានការងារធ្វើ | 4 | 0.15 | 0.60 |
| ៣. ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច | 4 | 0.10 | 0.40 |
| ៤. ភាពក្រីក្រ | 6 | 0.10 | 0.60 |
| ៥. វិសមភាព | 4 | 0.10 | 0.40 |
| ៦. សមធម៌យេនឌ័រ | 6 | 0.05 | 0.30 |
| ៧. សុខភាព និងអាហារូបត្ថម្ភ | 3 | 0.05 | 0.15 |
| ៨. ការអប់រំ | 4 | 0.05 | 0.20 |
| ៩. អនាម័យ និងទឹក | 4 | 0.05 | 0.20 |
| ១០. កិច្ចការពារខាងសង្គមកិច្ច | 2 | 0.10 | 0.20 |
| សរុប | | 1.00 | 5.05 |

សម្គាល់៖ ១-៣=លទ្ធផលមិនល្អ ៤-៧=លទ្ធផលល្អបង្គួរ ៨-១០=លទ្ធផលល្អប្រសើរ

ប្រភព៖ Mckinleg (២០១០) ដកស្រង់ពីក្នុងបទបង្ហាញរបស់បណ្ឌិត គុង គឹមស៊ុន ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា នៅថ្ងៃទី១៦ កុម្ភៈ ២០១២

មានលក្ខណៈសម្រាប់គ្រប់គ្នា។ ប៉ុន្តែ ការបំបែកនិន្នាការនេះជាផ្នែកតូចៗ បង្ហាញពី ផ្នែកមួយចំនួនដែលរដ្ឋាភិបាលត្រូវធ្វើសកម្មភាពដោះស្រាយ ដោយប្រើគោលនយោបាយខាងសេដ្ឋកិច្ច និងសង្គម។

## គោលនយោបាយម៉ាក្រូ និងមីក្រូសេដ្ឋកិច្ច

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជា កំណើន ផសស ជាប់លាប់ គឺជាកត្តាសំខាន់បំផុតដែលជំរុញកំណើនសម្រាប់គ្រប់គ្នា តាមរយៈការបង្កើតការងារ។ ដូច្នេះ ជាការសំខាន់ណាស់ដែលរដ្ឋាភិបាលត្រូវរក្សាឲ្យមានស្ថិរភាពនៅពេលអនាគត ជាពិសេស អត្រាអតិផរណាអាចគ្រប់គ្រងបាន (នៅក្រោម ៥% ជាការប្រសើរ)។

ប្រហែល ៩០% នៃគ្រួសារក្រីក្រ ពឹងផ្អែកលើការរកចិញ្ចឹមជីវិតនៅទីជនបទ ដូច្នេះ រដ្ឋាភិបាលត្រូវប្រឹងប្រែងទ្វេឡើងទៀតក្នុងការរៀបចំប្លឹងថ្លែងសេដ្ឋកិច្ចឡើងវិញ ដើម្បីឲ្យសមស្របតាមជាតុពិតនេះ។ វិធីសាស្ត្រទូទាំងវិស័យ (SWAp) សម្រាប់ពាណិជ្ជកម្ម ទទួលបានលទ្ធផលច្រើនគួរសមក្នុងការតម្រឹម និងបន្សុីធនធានរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីបំផុសឲ្យឃើញ និងលុបបំបាត់ឧបសគ្គរាំងកំណើនក្នុងវិស័យនាំចេញដែលមានឥទ្ធិពលខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ។ លទ្ធផលនេះត្រូវតែពង្រឹងឡើង តាមរយៈការពិនិត្យតាមដានជាបន្ត និងការបង្កើនសមត្ថភាពស្ថាប័ន។

ការអភិវឌ្ឍសម្រាប់គ្រប់គ្នាប្រកបដោយជោគជ័យ នឹងតភ្ជាប់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយមីក្រូសេដ្ឋកិច្ច ឲ្យនៅជាមួយគ្នា។ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ជាកត្តាចាំបាច់បំផុត បើសិនចង់ឲ្យកំណើនជ្រាបចូលទៅដល់តំបន់ភូមិសាស្ត្រដាច់ស្រយ៉ាល និងគ្រប់វិស័យ។ តំបន់ដាយៗជាកន្លែងប្រមូលផ្តុំភាពក្រីក្រ ដូច្នេះ ការបើកចំហតំបន់ទាំងនេះទៅកាន់ទីផ្សារនានា តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាកត្តាសំខាន់បំផុត។

កម្មវិធីគ្របដណ្តប់រួម ADB-GMS បានដើរតួនាទីស្នូលក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធនៅតាមច្រករបៀងសេដ្ឋកិច្ចសំខាន់ៗ ហើយវាបានតភ្ជាប់តំបន់ដាយៗរបស់ប្រទេសកម្ពុជា ទៅនឹងទីផ្សារជាតិ ទីផ្សារក្នុងតំបន់ និងលើពិភពលោក។

ការផ្តល់សេវាកម្មជួយបំពេញបន្ថែម ក៏ត្រូវមានដែរ ដើម្បីបង្កើនផលិតភាព ជាពិសេសក្នុងចំណោមប្រជាជនភាគច្រើនដែលរស់នៅជនបទ ដែលមានច្រើននាក់កំពុងធ្វើកសិកម្មលើដីតូចៗ។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានអនុវត្តគម្រោងធារាសាស្ត្រមួយចំនួនក្នុងទូទាំងប្រទេស ដោយផ្តោតកាន់តែច្រើនលើតំបន់មានអត្រាភាពក្រីក្រកម្រិតខ្ពស់ ជាអាទិ៍ គម្រោងធារាសាស្ត្រភាគព្វាសានទទួលមូលនិធិពីធនាគារ ADB ដែលមាន ១២ អនុគម្រោង សម្រាប់ផ្តល់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម និងសំណង់គ្រប់គ្រងទឹក ដើម្បីផ្តល់ទឹកស្រោចស្រពបន្ថែមនៅរដូវវស្សាដល់ដីស្រែ និងចម្ការប្រមាណ ១១.០០០ហិកតា។

មធ្យោបាយ ក៏ដូចជា គោលដៅកំពូលនៃការអភិវឌ្ឍ ត្រូវតែដើម្បីកំណើនសម្រាប់គ្រប់គ្នា។ តួយ៉ាង ការចូលរួមរបស់សហគមន៍កាន់តែមានបញ្ចូលច្រើនហើយ នៅក្នុងគ្រប់ដំណាក់កាលនៃការធ្វើផែនការ ការអនុវត្ត និងពិនិត្យតាមដានគម្រោងធារាសាស្ត្រកម្រិតមូលដ្ឋាន ដើម្បីធានាថា តម្រូវការក្នុងមូលដ្ឋានត្រូវបានដោះស្រាយ និងហើយការផ្តល់សេវាកម្មក៏បានប្រកបដោយសមធម៌។ ម្យ៉ាងទៀត មូលនិធិឃុំ/សង្កាត់ បានជួយលើកកម្ពស់របៀបរបបអនុវត្តរបស់សហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រង និងពិនិត្យតាមដានគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើនភាពជាម្ចាស់របស់សហគមន៍។

កង្វះខាតប្រព័ន្ធផ្តល់ឥណទានផ្លូវការ នៅតែជាឧបសគ្គបន្ថែមមួយចំពោះកសិករ និងអាជីវករសហគ្រាសខ្នាតតូចនិងមធ្យម ទោះបីក្នុងវិស័យនេះមានការរីកចម្រើនច្រើនហើយក្តី។ វិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា បានដើរតួនាទីឈានមុខក្នុងការពង្រីកសេវាកម្មហិរញ្ញវត្ថុផ្លូវការទៅដល់ប្រជាជនក្រីក្រនៅជនបទ។ ក្នុងប្រាំឆ្នាំចុងក្រោយ វិស័យនេះរីកលូតលាស់យ៉ាងលឿន ដោយមានអ្នកខ្ចីប្រាក់ដល់ទៅ ១,៣លាននាក់ និង អ្នកសន្សំប្រាក់ ១,១លាននាក់ ក្នុង ២៤ខេត្តក្រុង។ ប្រាក់បញ្ញើ កើន ៣២% ដល់១,២៦៣ពាន់លានដុល្លារ នៅឆ្នាំ២០១១ ធៀបនឹង ៩៥២លានដុល្លារ នៅឆ្នាំ២០១០។

ត្រូវមានគោលនយោបាយដោះស្រាយ បញ្ហាក្រឹត្យក្រមខាងសង្គម និងវប្បធម៌ដែលរារាំងស្ត្រីមិនឲ្យទទួលបានឱកាសសេដ្ឋកិច្ច។ ចំណែកដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រនារីរតនៈ III គឺ ការកសាងគោលនយោបាយកម្រិតជាតិដើម្បីលើកកម្ពស់សមធម៌យេនឌ័រ នៅក្នុងឱកាសសេដ្ឋកិច្ច។ កម្មវិធីនេះសំដៅញ៉ាំងឲ្យមានការផ្លាស់ប្តូរជាក់ស្តែងក្នុងគំរូយេនឌ័របែបវប្បធម៌ ដែលជួយសម្រួលឲ្យបុរសចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចមួយចំនួន ដូចជាក្នុងការទិញ ឬបន្តមរតកជាដើម តាមការជំរុញគោលនយោបាយដែលបំបាត់របាំងរារាំងស្ត្រី ក្នុងការចូលរួមក្នុងគ្រប់វិស័យសេដ្ឋកិច្ច។

រដ្ឋាភិបាលត្រូវបង្កើតមធ្យោបាយហិរញ្ញវត្ថុថែមទៀត តាមការបង្កើនការប្រមូលប្រាក់ចំណូល បើសិនចង់ឲ្យមានការរីកចម្រើនជានិរន្តរ៍ ក្នុងការអភិវឌ្ឍគោលនយោបាយ ស្ថាប័ន និងហេដ្ឋាចរនាសម្ព័ន្ធ។ រដ្ឋាភិបាលត្រូវប្តេជ្ញាចិត្តបង្កើនអត្រាប្រមូលប្រាក់ចំណូលឲ្យបាន ០.៥% ជារៀងរាល់ឆ្នាំ។ ក្របខ័ណ្ឌគោលនយោបាយសមស្រប ត្រូវតែបង្កើតឡើងទៀត ដើម្បីឲ្យទុននេះហុចផលបានច្រើនជាអតិបរមា និងបានជាប្រយោជន៍ដល់វិស័យទាំងឡាយដែលមានភាពក្រីក្រកម្រិតខ្ពស់នៅកម្ពុជា។

## គោលនយោបាយសង្គមជួយឲ្យមានកំណើនសម្រាប់គ្រប់គ្នា

កម្ពុជានៅយឺតយ៉ាវជាងប្រទេសឯទៀតក្នុងតំបន់ច្រើនណាស់ក្នុងការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ និង ប្រព័ន្ធការពារខាងសង្គមកិច្ច។

សេដ្ឋវិទូផ្នែកអភិវឌ្ឍន៍ មានបញ្ជាក់កាន់តែច្រើនគ្នាថា កង្វះប្រព័ន្ធការពារខាងសង្គមកិច្ច និងសេវាថែទាំសុខភាព ប៉ះពាល់ជាអវិជ្ជមានទៅ

លើអត្រាកំណើន និងរួមចំណែកឲ្យមាននិន្នាការកំណើនដែលមិនមែនសម្រាប់គ្រប់គ្នា។

កម្ពុជាមានពិន្ទុទាបក្នុងសូចនាករ ដូចជា ការការពារខាងសង្គមកិច្ចការអប់រំ ការថែទាំសុខភាព អាហារូបត្ថម្ភ អនាម័យនិងទឹកស្អាត ជាដើម។ សូចនាករទាំងនេះ សំខាន់ជាខ្លាំងចំពោះកំណើនសម្រាប់គ្រប់គ្នា ព្រោះសុខភាពល្អ និងសន្តិសុខខាងហិរញ្ញវត្ថុ វាជួយគ្រួសារក្រីក្រឲ្យចូលរួមក្នុងសេដ្ឋកិច្ចបានកាន់តែច្រើន។ ប្រសិនបើគ្រួសារក្រីក្រនៅតែតស៊ូឥតឈប់ឈរ ដើម្បីគ្រាន់តែដោះស្រាយតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់ខ្លួន ពួកគេកម្រមានផលិតភាពណាស់ ព្រោះរវល់តែរកឲ្យបានមួយរស់ៗ ហើយត្រូវជាប់ផុងក្នុងភាពក្រីក្រដដែល។

សង្គមស៊ីវិល បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់យន្តការគាំទ្រខាងសង្គមកិច្ចដល់ជនងាយរងគ្រោះ ហើយដៃគូអភិវឌ្ឍន៍នានាក៏បានជួយគាំទ្រយ៉ាងសកម្មដល់គម្រោងជាក់លាក់ជាច្រើនដែរ។ ឧទាហរណ៍ មូលនិធិអភិវឌ្ឍន៍ជួយជនក្រីក្រនៅទីក្រុង (UFPD) មានផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ការថែទាំសុខភាព និងការលើកកម្ពស់អនាម័យនៅតំបន់ទីក្រុង។ រដ្ឋាភិបាលបានគាំទ្រដល់កិច្ចប្រឹងប្រែងទាំងនេះ ហើយសម្តេចនាយករដ្ឋមន្ត្រី បានទាំងផ្តល់វិភាគទានផ្ទាល់ខ្លួនទៅឲ្យ UFPD ជារៀងរាល់ខែទៀតផង។

នៅកម្ពុជានាបច្ចុប្បន្ន មិនទាន់មានប្រព័ន្ធការពារខាងសង្គមកិច្ចដ៏ធំទូលាយមួយដែលគ្រប់គ្រងដោយរដ្ឋនោះទេ។ ការពឹងផ្អែកលើដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ធ្វើឲ្យការរីកចម្រើនក្នុងវិស័យនេះពុំមានចីរភាព ព្រោះភាគច្រើនត្រូវដើរតាមរបៀបវារៈរបស់អង្គការខុសៗគ្នាជាច្រើន។

នាពេលថ្មីៗនេះ រដ្ឋាភិបាលបានបង្កើតយុទ្ធសាស្ត្រជាតិការពារសង្គម (NSPS) ឆ្នាំ២០១១-១៥ មួយដែលកាន់តែគ្រប់ជ្រុងជ្រោយឡើង ដើម្បីដោះស្រាយបញ្ហាខ្វះខាតប្រព័ន្ធការពារខាងសង្គមកិច្ចនៅកម្ពុជា។ ក្របខ័ណ្ឌ NSPS បានកាត់តម្រឹមកម្មវិធីខាងសង្គមកិច្ចដែលមានស្រាប់ទាំងឡាយ ដោយផ្អែកលើក្របខ័ណ្ឌមួយធំទូលាយជាងមុន ដែលនឹងការពារជនក្រីក្រ និងជនងាយរងគ្រោះ ព្រមទាំងជួយសម្រួលឲ្យពួកគេបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចមានផលិតភាព។ ក្របខ័ណ្ឌនេះ រួមមាន ប្រព័ន្ធសុវត្ថិភាពសង្គមដើម្បីកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងប្រព័ន្ធផ្សេងៗទៀតសម្រាប់កែលំអអាហារូបត្ថម្ភ និងសុខភាពមាតានិងកុមារ លើកកម្ពស់ការអប់រំ និងលុបបំបាត់ពលកម្មកុមារ។

បញ្ហាប្រឈមដ៏ចម្បងមួយ គឺការបង្កើនលទ្ធភាពទទួលបានឱកាសការងារក្នុងសង្គម តាមការបង្រៀនជំនាញសមស្របដល់កម្លាំងពលកម្ម។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋាភិបាលបានបង្កើនជាបន្តបន្ទាប់ក្នុងមួយទសវត្សរ៍ចុងក្រោយនេះនូវចំណាយលើការអប់រំ ថ្វីបើចាប់តាំងពីឆ្នាំ២០០៨ មក ចំណាយនេះបានថយចុះបើគិតជាភាគរយនៃកញ្ចប់ថវិកាជាតិទាំងមូល ហើយបើសិនយកអត្រានេះមកប្រើ កម្ពុជាជាប់ចំណាត់ថ្នាក់មិនល្អទេ ធៀបនឹងប្រទេសជិតខាង។

អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅបឋមសិក្សា បានកើនឡើង ប៉ុន្តែអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា ក៏កើនឡើងដែរ ដោយវាជាប់ទាក់ទងជាសំខាន់ជាមួយស្ថានភាពគ្រួសារ។ ចំណុចនេះបង្ហាញពីចំណងទាក់ទងមិនអាចកាត់ផ្តាច់បាន រវាងការការពារផ្នែកសង្គមកិច្ច និងការរៀនសូត្រ។

បញ្ហាកាន់តែបន្ទាន់មួយទៀត គឺ ជារៀងរាល់ឆ្នាំមានជនវ័យក្មេងពី ៣០០.០០០ ទៅ ៤០០.០០០នាក់ ចូលទៅក្នុងទីផ្សារពលកម្ម។ ជនទាំងនេះត្រូវមានជំនាញសមស្រប ប្រសិនបើចង់ទទួលបានឱកាសការងារផុសចេញពីកំណើនសេដ្ឋកិច្ច និងពិពិធកម្មសេដ្ឋកិច្ច។ ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ (TVET) ផ្សេងៗ គួរតែប្រមែប្រមូលមកឲ្យបង្រៀនជំនាញដល់កម្លាំងពលកម្មចំណូលថ្មីទាំងនេះ និងពង្រីកទៅដល់វិស័យកសិកម្ម និងតំបន់ជាយៗថែមទៀត។

## ភាពមិនស៊ីគ្នារវាង គោលនយោបាយ-ស្ថាប័ន និងការសម្រេចឲ្យបានកំណើនសម្រាប់គ្រប់គ្នា

រដ្ឋាភិបាល បានបង្កើត និងដាក់អនុវត្តនូវក្របខ័ណ្ឌគោលនយោបាយផ្តួចផ្តើមថ្មីជាច្រើន ដែលបានដំណើរការយ៉ាងល្អ ឈានទៅសម្រេចបានគោលដៅនៃកំណើនសម្រាប់គ្រប់គ្នា។ ទោះយ៉ាងនេះក្តី ទ្រឹស្តីលើបញ្ហានេះ បានបញ្ជាក់ថា មានតែសមត្ថភាពស្ថាប័នទេ ដែលជាកូនសោនៃការអភិវឌ្ឍសម្រាប់គ្រប់គ្នា។ ក្របខ័ណ្ឌគោលនយោបាយ ដូចជា NSPS និង SWAp មានឥទ្ធិពលខ្លាំងហើយ ប៉ុន្តែបញ្ហាចោទ គឺការអនុវត្តគោលនយោបាយទាំងនេះ។

ភាពមិនស៊ីគ្នារវាងស្ថាប័ន និងគោលនយោបាយ អាចមានផលប៉ះពាល់អវិជ្ជមានទៅលើការអភិវឌ្ឍសម្រាប់គ្រប់គ្នា ហើយចំណុចនេះអាចមើលឃើញច្បាស់បំផុតក្នុងបញ្ហាដីធ្លី។

ដីធ្លីសំខាន់ខ្លាំងណាស់សម្រាប់គ្រួសារក្រីក្រ ព្រោះអាចគួបផ្សំជាមួយកម្លាំងពលកម្ម (សម្បត្តិចម្បងរបស់គ្រួសារក្រីក្រ) ដើម្បីបង្កើតប្រាក់ចំណូល។ ដូច្នេះ សិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព គឺជាលក្ខខណ្ឌដ៏ចាំបាច់នៃកំណើនសម្រាប់គ្រប់គ្នា។ ក្របខ័ណ្ឌគោលនយោបាយ បានទទួលស្គាល់កម្មសិទ្ធិស្របច្បាប់លើដីធ្លីក៏ពិតមែន ប៉ុន្តែស្ថាប័នសម្រាប់ពង្រឹងអនុវត្តច្បាប់មិនបានរីកលូតលាស់លឿនដូចច្បាប់ទេ។ ជាលទ្ធផលមានទំនាស់ដីធ្លីកើតឡើងច្រើនណាស់ និងមានករណីរឿងក្តីនៅច្រើនកកកុញនៅឯគណៈកម្មាធិការសុរិយោដី ធ្វើឲ្យប្រជាជនបាត់បង់ទំនុកចិត្តលើសុវត្ថិភាពកាន់កាប់ដីធ្លី ហើយការរួមចំណែកក្នុងសេដ្ឋកិច្ចត្រូវជួបឧបសគ្គ។

ចំណុចខ្វែងគំនិតគ្នាធំមួយ គឺការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច (ELDs)។ ក្នុងការងារនេះ ក៏មានគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់បែងចែក និងពិនិត្យតាមដាន ELCs ដែរ ប៉ុន្តែក្នុងករណីខ្លះក្របខ័ណ្ឌទាំងនេះគេមិនបានអនុវត្តតាមទេ ធ្វើឲ្យការប្រើប្រាស់ដីពុំមានប្រសិទ្ធភាពគ្រប់គ្រាន់ ហើយបង្កឧបសគ្គដល់ការចូលរួមក្នុងសកម្មភាពបង្កើតមូលធនរបស់គ្រួសារនៅតាមមូលដ្ឋាន។

កំណែទម្រង់ស្ថាប័នមូលដ្ឋាន ដែលដើរតួនាទីគន្លឹះក្នុងជីវភាពប្រចាំថ្ងៃរបស់គ្រួសារនានា ក៏សំខាន់ណាស់ដែរសម្រាប់ការចូលរួមឲ្យបានគ្រប់ៗគ្នាក្នុងសកម្មភាពសេដ្ឋកិច្ច-សង្គមកិច្ច។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល បានធ្វើការកែទម្រង់ក្រុមប្រឹក្សាឃុំឲ្យកាន់មានសមធម៌ ប្រសិទ្ធភាព និងតម្លាភាព ក្នុងការផ្តល់សេវាកម្ម និងការគ្រប់គ្រងសហគមន៍មូលដ្ឋាន៕

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@cdri.org.kh, website: http://www.cdri.org.kh